**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...១០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែមាត្រា ២ នៃអនុក្រឹត្យស្តីពី ការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីការកែប្រែមាត្រា២នៃអនុក្រឹត្យ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រាតែមួយ .-**

មាត្រា ២ថ្មី នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីការកែប្រែមាត្រា២ នៃអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវបានកែសម្រួលដូចតទៅ :

**មាត្រា ២ ថ្មី** : សភាពាណិជ្ជកម្មរាជធានីភ្នំពេញ មានសមាជិកជ្រើសតាំងចំនួន ៤០ រូប ( សែសិប) ដែលជ្រើសរើសតាមការបោះឆ្នោត ស្របតាមលក្ខខណ្ឌដែលបានកំណត់ដោយអនុក្រឹត្យដោយឡែក ហើយត្រូវបានបែងចែកតាមប្រភេទអាជីវកម្មនីមួយៗ ដូចតទៅ :

| | |
|---|---|
| ១-ប្រភេទពាណិជ្ជកម្ម | ១២ រូប |
| ២-ប្រភេទឧស្សាហកម្ម និងសិប្បកម្ម | ១២ រូប |
| ៣-ប្រភេទសេវាកម្ម និងវិជ្ជាជីវៈសេរី | ១០ រូប |
| ៤-ប្រភេទកសិកម្ម | ០៦ រូប |

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលរាជធានីភ្នំពេញ និងប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ដូចមាត្រា៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ